Department of Primary Industries

ប័ណ្ណពត៌មាន 8

# រក្សាវាឲ្យបានស្អាតសំរាប់ទីវាលដាំបន្លែ

## ការគ្រប់គ្រងលើរុក្ខជាតិតូចៗឥតប្រយោជន៍ ដើមឈើដាំជាជួរសំរាប ទប់ខ្យល់ និងទឹក

Virginia Brunton & Jeremy Badgery-Parker, Ourimbah

## រុក្ខជាតិតូចៗឥតប្រយោជន៍

រុក្ខជាតិជាច្រើនដែលគេជួបប្រទះនៅជុំវិញចំការ គឺជាកន្លែងរស់នៅរបស់សត្វល្អិតចង្រៃ សត្វព្រូន និងជម្ងឺដែលអាចយាយីដល់ដំណាំទូទៅបាន។ ផែនការគ្រប់គ្រងលើរុក្ខជាតិតូចៗឥតប្រយោជន៍ គឺជាផ្នែកសំខាន់នៃការការពារសត្វចង្រៃដែលបណ្តាលឲ្យខូចខាតដល់ដំណាំ។ ការគ្រប់គ្រងលើរុក្ខជាតិតូចៗឥតប្រយោជន៍ដែលមានប្រសិទ្ធិភាព ទាក់ទិននឹងការស្គាល់ថារុក្ខជាតិណាដែលជាស្មៅឥតប្រយោជន៍ និងការពុំទុកឲ្យវាដុះលូតលាស់។ អាចមានរុក្ខជាតិមួយចំនួន ដែលជារុក្ខជាតិតូចៗឥតប្រយោជន៍ដែលគេបានរៀបចំឡើងក្នុងកន្លែងនៅសាលាក្រុងដែលត្រូវបំបាត់ ឬបំផ្លាញវាចោលតាមច្បាប់ ទោះបីជាវាពុំបង្កើតបញ្ហាដោយផ្ទាល់ដល់ដំណាំរបស់លោកអ្នកក៏ដោយ។

> *“ ត្រូវថែរក្សាកុំឲ្យមានរុក្ខជាតិតូចៗឥតប្រយោជន៍ នៅកន្លែងផលិតភោគផលដំណាំ និងចំការដែលនៅជុំវិញ ”*

ផែនការគ្រប់គ្រងលើរុក្ខជាតិតូចៗឥតប្រយោជន៍ ដែលបានអនុវត្តតាមទម្លាប់ គឺជាការសំខាន់។ ការដាំដំណាំឆ្លាស់គ្នាតាមរដូវ ការដាំបណ្តុះមុនពេលបាញ់ស្រោចថ្នាំសម្លាប់រុក្ខជាតិតូចៗ ឬស្មៅចង្រៃមុនពេលវាចេញពន្លកដែលគេបានជ្រើសរើស និងដែលមានកម្លាំងខ្លាំងក្លា គឺជាផ្នែកទាំងអស់នៃដំណោះស្រាយក៏ដូចជាការកាត់បន្ថយការចូលមកដល់នៃគ្រាប់ពូជ តាមរយៈវត្ថុធាតុដែលគេលាយជាមួយដីដើម្បីកែប្រែគុណភាពដី កូនឈើតូចៗ ឬដីនៅជិតខាងដូច្នេះដែរ។ គោលបំណងគឺដើម្បីកាត់បន្ថយពំនូកគ្រាប់ពូជរបស់រុក្ខជាតិតូចៗឥតប្រយោជន៍ឲ្យមានចំនួនតិចបំផុត និងធ្វើឲ្យចំនួនគ្រាប់ពូជចូលមកចំការរបស់លោកអ្នកមានតិចបំផុត។ ជំរើសនៃការគ្រប់គ្រង នឹងប្រែប្រួលទៅតាមស្ថានភាព (ឧទាហរណ៍ រវាងដំណាំ ឬរដូវ នៅចន្លោះ ឬនៅក្នុងរងដំណាំនៅតាមគន្លងន័ង្គល ឬនៅតាមបណ្តោយបំពង់នាំទឹកបាញ់ស្រោច នៅជាយទីវាលស្មៅដែលមានរបងព័ទ្ធជុំវិញ ផ្លូវថ្នល់ ឬស្នាមដាន) ក៏ប៉ុន្តែចាំបាច់ត្រូវគិត និងត្រូវរៀបចំគម្រោងអំពីការនេះ។ ការដាក់ទុនទៅលើឧបករណ៍ដាំបណ្តុះនៅចន្លោះរងដំណាំ ដោយប្រើសំរាមក្នុងពំនូករុក្ខជាតិ និងការដាំដំណាំឆ្លាស់គ្នាតាមរដូវ ទាំងអស់នេះគឺជាជំរើសនៃការគ្រប់គ្រងលើរុក្ខជាតិតូចៗឥតប្រយោជន៍ដោយពុំប្រើសារធាតុគីមី ដែលអាចត្រូវបានប្រើតែឯង ឬ ដើម្បីកាត់បន្ថយលទ្ធភាព កើនឡើងនូវការប្រឆាំងទប់ទល់នឹងថ្នាំសម្លាប់រុក្ខជាតិតូចៗ ឬស្មៅចង្រៃ។

នៅលើចំការមួយចំនួន ការកាត់ស្មៅឲ្យបានទៀងទាត់អាចជាជំរើសចូលចិត្តជាងគេសំរាប់ការត្រួតពិនិត្យលើរុក្ខជាតិតូចៗ ឬស្មៅចង្រៃ។ ចូររក្សាស្មៅឲ្យនៅខ្លីជាប្រចាំ និងកុំឲ្យមានរុក្ខជាតិដែលមានស្លឹកធំៗ និងចេញផ្កាឡើយ។

នៅជុំវិញកន្លែងដំណាំដាំដុះ ត្រូវការឲ្យមានកន្លែងដែលពុំមានរុក្ខជាតិតូចៗ ឬស្មៅចង្រៃឡើយ - សូម្បីតែកូនឈើទើបដុះនៃរុក្ខជាតិតូចៗ ឬស្មៅចង្រៃក៏ពុំត្រូវឲ្យមានដែរ។ កន្លែងនេះទើបអាចជាតំបន់បន្ថយគ្រោះថ្នាក់ទំហំ៥-១០ម៉ែត្រ ដែលនៅជាប់នឹងដំណាំដែលត្រូវបានរក្សាពុំឲ្យមានរុក្ខជាតិអ្វីទាំងអស់។ ចំពោះកន្លែងតូចៗនៅរវាងរោង ឬរចនាសម្ព័ន្ធដទៃទៀត ចូរក្រាលទីដីជាមួយនឹងកម្រាលនៃរុក្ខជាតិតូចៗឥតប្រយោជន៍ គ្រួសល្អិត ឬសំរាមរុក្ខជាតិដើម្បីការពារកុំឲ្យរុក្ខជាតិដុះឡើងបាន។ ដើម្បីឲ្យបានលទ្ធផលល្អជាងនេះ ចូររក្សាទុកកន្លែងដែលពុំមានដុះរុក្ខជាតិតូចៗឥតប្រយោជន៍ ឲ្យបានធំជាងនេះ ជាពិសេសនៅលើផ្នែកនៃដីកម្មសិទ្ធិ ដែលនៅចំទិសមានខ្យល់រដូវក្តៅជាញឹកញាប់។

យុទ្ធសាស្ត្រដែលមានប្រយោជន៍ គឺត្រូវរៀបចំគម្រោង និងធ្វើការជាមួយអ្នកជិតខាង ដើម្បីបង្កើតឲ្យមានកន្លែងសំរាប់កម្មវិធីគ្រប់គ្រងរុក្ខជាតិតូចៗ ឬស្មៅចង្រៃដ៏ទូលំទូលាយ។ ក្នុងតំបន់មួយចំនួន យុទ្ធសាស្ត្រធ្វើឲ្យពពួកបន្លែក្នុងស្រុកដុះឡើងវិញ ត្រូវបានបង្កើតឡើងដោយការប្រើពូជរុក្ខជាតិដែលគេបានជ្រើសរើស ដែលមិនមែនជាកន្លែងជ្រកពួនសំរាប់ពពួកសត្វចង្រៃនោះឡើយ។

## ដើមឈើដាំជាជួរសំរាប់ទប់ខ្យល់ និងរបាំងរុក្ខជាត

សត្វល្អិតចង្រៃ រុក្ខជាតិតូចៗឥតប្រយោជន៍ និងជម្ងឺជាច្រើនបានឆ្លងរាលដាលដោយសារខ្យល់។ ការដាក់ឲ្យមានដើមឈើដាំជាជួរសំរាប់ទប់ខ្យល់ជុំវិញចំការ ឬជុំវិញកន្លែងផលិតភោគផល អាចកាត់បន្ថយចំនួនសត្វចង្រៃដែលអាចត្រូវបាននាំចូលក្នុងទីវាល។ ដើមឈើដាំជាជួរសំរាប់ទប់ខ្យល់អាចជារចនាសម្ព័ន្ធដូចជារបាំងរបង ឬជាទូទៅច្រើនតែជារបងរុក្ខជាតិ។ មានរបៀបជាក់លាក់សំរាប់សាងសង់ ឬដាំដើមឈើជាជួរដើម្បីទប់ខ្យល់ឲ្យមានប្រសិទ្ធិភាព។ មានវិធីណែនាំយ៉ាងសាមញ្ញពីរបីអំពីរបៀបទាំងនេះ។

នៅពេលដាំដើមឈើជាជួរសំរាប់ទប់ខ្យល់ ចូរប៉ុនប៉ងប្រើប្រាស់រុក្ខជាតិ៣ជួរ។ ចូរប្រើប្រាស់ប្រភេទរុក្ខជាតិដែលមានពណ៌ខៀវស្រងាត់គ្រប់រដូវ តាមចំណូល

ចិត្តជាងគេ គឺរុក្ខជាតិក្នុងស្រុកដែលដុះនៅកន្លែងរបស់លោកអ្នក។ របងរុក្ខជាតិនឹងផ្តល់កិច្ចការពារប្រហែល៦ដងនៃកំពស់រុក្ខជាតិ។ ឧទាហរណ៍ របងដើមឈើកំពស់៣ម៉ែត្រ នឹងផ្តល់កិច្ចការពារសំរាប់ប្រហែល១៨ម៉ែត្រ។

ដើម្បីជៀសវាងការជះស្រមោល ដើមឈើដាំជាជួរសំរាប់ទប់ខ្យល់ចាំបាច់ត្រូវមានចម្ងាយពីទីវាលឲ្យបាន២-៣ដងនៃកំពស់ដើមឈើ។ ចម្ងាយនេះនឹងប្រែ



ប្រួលទៅតាមសណ្ឋានដីរបស់ទីតាំង។

របងរុក្ខជាតិទប់ខ្យល់ ក៏អាចផ្តល់ជាជំរកសំរាប់អតិសុខុមប្រាណដែលមានគុណប្រយោជន៍ផងដែរ ដូចជាសត្វស្លាប ពីងពាង និងសត្វល្អិតស៊ីសាច់ ដែលអាចជួយកាត់បន្ថយសត្វចង្រៃលើចំការរបស់លោកអ្នក។ គឺជាការសំខាន់ដែលត្រូវគិតដោយប្រុងប្រយ័ត្ន អំពីប្រភេទរុក្ខជាតិដែលត្រូវប្រើប្រាស់ ដើម្បីជៀសវាងការបង្កើតបញ្ហានៅលើទីកន្លែង។

## ការគ្រប់គ្រងទឹក

ទឹកគឺជាផ្នែកសំខាន់ចាំបាច់សំរាប់ការផលិតភោគផលបន្លែ។ របៀបយ៉ាងណាដែលត្រូវគ្រប់គ្រងទឹកនៅលើដីកម្មសិទ្ធិ និងស្រោចស្រប់ទៅលើដំណាំនឹងមានការប៉ះទង្គិចទៅលើការគ្រប់គ្រងសត្វចង្រៃ។ ការផ្គត់ផ្គង់ទឹកស្អាតគុណភាពទឹកដែលអាចទុកចិត្តបាន គឺជាការចាំបាច់។

ចូរឲ្យប្រាកដច្បាស់ថា លោកអ្នកយល់ដឹងពីរបៀបដែលពេលវេលាបាញ់ស្រោចទឹកអាចប៉ះទង្គិចទៅលើការគ្រប់គ្រងជម្ងឺ។ ឧទាហរណ៍ ភាពសើមនៃស្លឹករុក្ខជាតិដែលបន្ទាយពេលយូរ អាចនាំឲ្យឧប្បត្តិហេតុនៃជម្ងឺដុះផ្សិតកើនឡើងដូចជាជម្ងឺ downy mildew ជាដើម។

> *“ ចូរគ្រប់គ្រងការបាញ់ស្រោចទឹក និងសារធាតុចិញ្ចឹមឲ្យបានប្រសើរបំផុតសំរាប់សេចក្តីត្រូវការរបស់រុក្ខជាតិ ”*

ប្រព័ន្ធបង្ហូរទឹកល្អជុំវិញចំការមានសារៈសំខាន់ ក្នុងការកាត់បន្ថយហានិភ័យដោយជម្ងឺដែលនឹងឆ្លងទៅក្នុងដំណាំ។ ប្រព័ន្ធបង្ហូរទឹកចាំបាច់ត្រូវរៀបចំគម្រោងការតាមសភាពការណ៍នៃផ្លូវថ្នល់ និងសណ្ឋានដីរបស់ចំការ។ ចូរធ្វើប្រាកដច្បាស់ថា ទឹកដែលហៀរហូរមកលើផ្ទៃដី និងទឹកហូរមកពីប្រភពផ្សេងៗដែលមិនបានបឺតស្រូបចូលទៅក្នុងដី ពុំអាចនាំយកសំរាម និងកំទេចសំណល់ទៅក្នុងកន្លែងដាំដុះ ឬទៅលើផ្លូវថ្នល់បានឡើយ។ ចូរការពារកុំឲ្យរុក្ខជាតិដែលគ្មានទង គ្មានមែកដូចជាស្លែសារាយដុះលូតលាស់ក្នុងបំពង់បង្ហូរទឹក ប្រឡាយទឹក និងក្នុងកន្លែងឯទៀតរបស់ចំការឡើយ។

គឺជាការសំខាន់ដែលពុំត្រូវមានកន្លែងទន់ ហើយសើម ឬគ្រលុកដក់ទឹកនៅក្នុងតំបន់ “ស្អាត” ឡើយ។ គ្រលុកដក់ទឹក និងកន្លែងមានភក់ គឺជាទីដីដែលចិញ្ចឹមសត្វល្អិត ចង្រៃ និងជម្ងឺមួយចំនួន។ កន្លែងទាំងអស់នេះចាំបាច់ត្រូវបង្ហូរទឹកចេញ ឬចាក់បំពេញ។ ការនេះធ្វើឲ្យងាយស្រួលច្រើនក្នុងការរក្សាចំការឲ្យបានស្អាត។ ចូរថែទាំផ្លូវថ្នល់ និងផ្លូវលំជុំវិញទីវាល ដើម្បីការពារកុំឲ្យគ្រលុកដក់ទឹកករកើតបាន និងរក្សាបំពង់បង្ហូរទឹកឲ្យស្រឡះល្អ ដើម្បីជៀសវាងកុំឲ្យស្ទះលេចទឹក។

ប្រសិនបើលោកអ្នកផលិតឡើងវិញនូវទឹកបាញ់ស្រោចដែលបានប្រើរួចហើយ គឺជាការសំខាន់ដែលត្រូវត្រួតពិនិត្យការផ្ទុកសារធាតុបង្ករោគទៅក្នុងអាងទឹករបស់លោកអ្នក និងទុកឲ្យប្រព័ន្ធច្រោះបំបាត់ ឬកាត់បន្ថយលទ្ធភាពនាំជម្ងឺត្រាច់ចរទៅមក

នៅពេលលោកអ្នកបាញ់ស្រោចទឹកម្តងទៀត។

ការទទួលស្គាល់: ពត៌មាននៅក្នុងការបោះពុម្ពផ្សាយនេះ បានរៀបចំចេញពី រក្សាវាឲ្យបានស្អាត – កាត់បន្ថយការចំណាយ និងការខាតបង់ក្នុងការគ្រប់គ្រងសត្វចង្រៃ និងជម្ងឺនៅក្នុងរោងដាំបន្លែ និងកូនរុក្ខជាតិ។ Badgery-Parker, J and T Burfield 2009 ជាមួយនឹងគំនិត និងឱវាទបានមកពី Sandra McDougall និង Alison Anderson។

© រដ្ឋញូវសៅវែល តាមរយៈក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ ឆ្នាំ២០១០។ លោកអ្នកអាចចម្លង ចែកចាយ និងដោះស្រាយជាមួយនឹងការបោះពុម្ពផ្សាយតាមរបៀបផ្សេងពីនេះដោយសេរី ដើម្បីគោលបំណងណាមួយ គឺឲ្យតែលោកអ្នកបានបញ្ជាក់ថាក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ គឺជាម្ចាស់កម្មសិទ្ធិនៃការបោះពុម្ពផ្សាយនេះ។

ISSN 1832-6668

ការប្រកាសមិនទទួលខុសត្រូវ: ពត៌មាននៅក្នុងការបោះពុម្ពផ្សាយនេះ គឺសំអាងលើចំណេះដឹង និងការយល់ដឹងនៅក្នុងពេលកំពុងសរសេរ (ខែមីនា ឆ្នាំ២០១២)។ ទោះជាយ៉ាងនេះក្តី ដោយសារការជឿនលឿនផ្នែកចំណេះដឹង អ្នកប្រើប្រាស់ត្រូវបានរំលឹកអំពីសេចក្តីត្រូវការដើម្បីឲ្យប្រាកដច្បាស់ថា ពត៌មានដែលគេពឹងផ្អែកទៅលើ មានលក្ខណៈទាន់ពេល និងសំរាប់ឆែកមើលបច្ចុប្បន្នភាពនៃពត៌មានជាមួយភ្នាក់ងារសមស្របរបស់ក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម ឬអ្នកផ្តល់ឱវាទឯករាជ្យសំរាប់អ្នកប្រើប្រាស់។

ចុះផ្សាយដោយក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម ដែលជាផ្នែកមួយរបស់ក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ។

Trim reference INT 12/24532

Horticulture Australia

ការផលិតប័ណ្ណពត៌មាននេះ និងការបកប្រែភាសាបានទទួលការផ្គត់ផ្គង់ប្រាក់មួយ ចំណែកពីគំរោងដែលទទួលប្រាក់ឧបត្ថម្ភរបស់ HAL អង្គការដំណាំវប្បកម្មអូស្ត្រាលី): *ការដោះស្រាយអំពីគុណភាព និងសុវត្ថិភាពនៃផលិតផលជាមួយអ្នកដាំដុះនៃឧស្សាហកម្មបន្លែដែលនិយាយភាសាក្រៅពីភាសាអង់គ្លេស* ការផ្តើមគំនិតនៃកម្មវិធីអភិវឌ្ឍន៍ឧស្សាហកម្មបន្លែ។